ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**
-លេខ ១៤ -ទ-
ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងរដ្ឋប្បវេណីលេខ ៨១
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមជំនុំជម្រះ**
លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ
**ក្រឡាបញ្ជី**
លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-ដើមចោទ និងជាចុងបណ្តឹងតប៖** ឈ្មោះ [redacted] ចាន់លីណា ភេទស្រី កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted]។

**-អ្នកតំណាងដោយអាណត្តិ៖** មេធាវី [redacted] អត្តលេខ២៧២៩T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅការិយាល័យមេធាវី នីតិរដ្ឋ ស្ថិតនៅអគារ [redacted] និងមេធាវី [redacted] ជាមេធាវីនៅក្រុមមេធាវី កិត្តិគុណ មានការិយាល័យផ្ទះលេខ [redacted]។

**-ចុងចម្លើយ និងជាដើមបណ្តឹងតប៖** ឈ្មោះ [redacted] ទិត ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted]។

**-អ្នកតំណាងដោយអាណត្តិ៖** មេធាវី [redacted] អត្តលេខ១០៤១ ជាមេធាវីនៅការិយាល័យមេធាវី [redacted] ការិយាល័យមានទីតាំងនៅផ្លូវជាតិលេខ [redacted] (ក្រោយស្ថានីយប្រេងPTT) [redacted]។

## I. អង្គហេតុ និងចំណុចវិវាទ

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទ និងជាចុងបណ្តឹងតបទាមទារឲ្យតុលាការចេញ**

១.១-សុំលែងលះរវាងឈ្មោះ [redacted]ាន់លីណា និងប្តីឈ្មោះ [redacted] ទិត

១.២- សុំសិទ្ធិគ្រប់គ្រងកូន០២នាក់

ក.ឈ្មោះ [redacted] តារា ភេទប្រុស កើតនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣

ខ.ឈ្មោះ [redacted] សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។

១.៣-ការទទួលខុសត្រូវលើបំណុលរួមដែលនៅជំពាក់ពីការខ្ចីបង្កើតមុខរបរ និងមើលជម្ងឺ ចំនួន ១៣០.០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក ដើមចោទរ៉ាប់រងទទួលខុសត្រូវសង។

**២. ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយ និងជាដើមបណ្តឹងតបទាមទារឲ្យតុលាការចេញ**

២.១-សុំទុកជាមោឃភាពនូវពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចាន់លីណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ជាអសារបង់។



Scanned with CamScanner

២.២-សុំឲ្យតុលាការចេញសេចក្តីសម្រេចលុបចោលកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] ទិត និងឈ្មោះ [redacted] ចាន់លីណា។

២.៣-សុំទាមទារកូនប្រុសច្បងឈ្មោះ [redacted] តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។

២.៤-សុំឲ្យឈ្មោះ [redacted] ចាន់លីណា ប្រគល់ប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក មកឲ្យឈ្មោះ [redacted] ទិត ដែលជាប្រាក់បានមកពីការរកស៊ីរួមគ្នា និងប្រាក់ដែលបានមកពីការលក់ដី និងសល់ពីថ្លៃព្យាបាលជម្ងឺឈ្មោះ [redacted] ទិត។

## ៣. ដំណើររឿងក្តី និងចំណុចខុសខាង

### ៣.១. ការសង្ខេបអំពីរឿងក្តី

ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីណា និងចុងចម្លើយឈ្មោះ [redacted] ទិត បានរស់ជាមួយគ្នាជាប្តីប្រពន្ធនៅឆ្នាំ២០១៣ ក៏ទទួលបានកូនប្រុសម្នាក់ ក្រោយមកក៏បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់នៅឆ្នាំ២០១៤។ លុះចូលដល់ឆ្នាំ២០១៦ ដើមចោទ និងចុងចម្លើយក៏មានកូនប្រុសម្នាក់ទៀត។

នៅអំឡុងឆ្នាំ២០២០ ចុងចម្លើយឈ្មោះ [redacted] ទិត បានជួបគ្រោះថ្នាក់ការងារដោយឆក់ខ្សែភ្លើងធ្លាក់ពីលើបង្គោលភ្លើង ដើមចោទបានយកចុងចម្លើយទៅព្យាបាលនៅប្រទេសវៀតណាម តែចុងចម្លើយមិនមានស្មារតីដូចពីមុនឡើយ និងមិនអាចវិលទៅធ្វើការធម្មតាបានដូចមុន លុះពេលត្រឡប់មកខ្មែរវិញដោយសារចុងចម្លើយរវល់មើលថែរកូន និងលក់ដូរមិនមានពេលគ្រប់គ្រាន់មើលថែរប្តី ក៏សុំឲ្យម្តាយក្មេកជួយមើលថែរប្តី រហូតដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដើមចោទនិងចុងចម្លើយក៏បានធ្វើកិច្ចសន្យាព្រមព្រៀងលែងលះ ដោយឲ្យកូនទាំង២នាក់ទៅដើមចោទគ្រប់គ្រង រីឯបំណុលចំនួន១៣០.០០០(ដប់បីម៉ឺន)ដុល្លារអាមេរិក ដើមចោទទទួលរ៉ាប់រងទទួលខុសត្រូវសងទាំងអស់ ដោយមិនទាមទារអាហារកិច្ច។ ដោយសារដើមចោទ និងចុងចម្លើយមានសំបុត្រអាពាហ៍ពិពាហ៍ ដើមចោទក៏បានដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។

### ៣.២.ការអះអាងរបស់ភាគីៈ

**+ចំពោះបណ្តឹង ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣**

**- ការអះអាងរបស់ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីនណា តំណាងដោយអាណត្តិដោយមេធាវី [redacted] និងមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថាៈ**

ខ្លួននៅតែរក្សាការទាមទារដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ នៅដដែល។ ដោយបញ្ជាក់បន្ថែមថា នៅឆ្នាំ២០១៣ ខ្លួននិងចុងចម្លើយ ស្រលាញ់គ្នារស់នៅជាមួយគ្នាក៏ទទួលបានកូនប្រុស០១នាក់ឈ្មោះ [redacted] **តារា** ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដល់ចូលឆ្នាំ២០១៤ ខ្លួន និងចុងចម្លើយសម្រេចចិត្តជាមួយគ្នា ចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយប្តីប្រពន្ធស្របច្បាប់ លុះដល់ចូលឆ្នាំ២០១៦ ខ្លួននិងចុងចម្លើយមានកូនប្រុសម្នាក់ទៀត ឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។ ខ្លួននិងចុងចម្លើយរួមរស់នៅជាមួយគ្នាមានសេចក្តីសុខ មានសុភមង្គល លុះដល់ឆ្នាំ២០២០ មានគ្រោះទុក្ខបំផ្លាញសុភមង្គលគ្រួសារខ្លួន ចុងចម្លើយបានជួបគ្រោះថ្នាក់ការងារដោយឆក់ខ្សែភ្លើងធ្លាក់ពីលើបង្គោលភ្លើង ខ្លួនបានយកចុងចម្លើយទៅព្យាបាលនៅប្រទេសវៀតណាម ដោយរស់រានមានជីវិតតែស្មារតីមិនដូចមុនឡើយ មិនអាចវិលទៅធ្វើការដូចមុនធម្មតាបាន លុះមកដល់ខ្មែរវិញខ្លួនមើលថែគាត់បានមួយរយៈ ដោយខ្លួនរវល់ថែរកូន និងលក់ដូរមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ថែរប្តីបាន។ មូលហេតុដែលខ្លួនលែងលះ ព្រោះខ្លួនមិនមានលទ្ធភាពមើលថែរគាត់បាន ធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។

សព្វថ្ងៃខ្លួន និងចុងចម្លើយបានរស់នៅបែកសង្វាសគ្នា០៣ឆ្នាំមកហើយ។



Scanned with CamScanner

មូលហេតុដែលខ្លួនសុំសិទ្ធិគ្រប់គ្រងកូនប្រុសពីរនាក់ ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៣ និងឈ្មោះ [redacted] សំណាង ភេទប្រុស កើតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ដោយសារកូនទាំងពីរជាកូនរបស់ខ្លួនបង្កើតជាមួយចុងចម្លើយប្រាកដមែន ដោយសារប្តីរបស់ខ្លួនមានជម្ងឺមិនអាចគ្រប់គ្រងរក្សាកូនបាន ខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនរហូតដល់កូនមានការងារធ្វើ។ ខ្លួនមានមុខរបរលក់ដូរនៅផ្សារ អាចមានពេលវេលាគ្រប់គ្រាន់សម្រាប់មើលថែរកូន។

ខ្លួនពុំឯកភាពឲ្យកូនប្រុស ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ឲ្យទៅចុងចម្លើយឡើយ ដោយសារគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់សម្រាប់មើលថែកូនឡើយ គាត់អាចមកលេងសួរសុខទុក្ខកូន ឬយកកូនទៅលេងបាននៅពេលដែលកូនសម្រាកពីការរៀនសូត្រ ខ្លួនមិនទាមទារអាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនឡើយ។

**-ការអះអាងរបស់ចុងចម្លើយ និងជាដើមបណ្តឹងតប ឈ្មោះ [redacted] ទិត តំណាងដោយអាណត្តិដោយមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖**

ការលើកឡើងរបស់ដើមចោទពិតជាត្រឹមត្រូវ ខ្លួនឯកភាពលែងលះពីដើមចោទ ដោយសារការរួមរស់ជាមួយគ្នា មិនអាចរួមភេទជាមួយគ្នាបានធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ហើយសព្វថ្ងៃខ្លួនរស់នៅបែកសង្វាសគ្នាចំនួន០៣ឆ្នាំដូចការលើកឡើងរបស់ដើមចោទ។

ខ្លួនពុំឯកភាពក្នុងការផ្តល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ខាងលើឲ្យដើមចោទទេ គឺខ្លួនសុំសិទ្ធិគ្រប់គ្រងកូនម្នាក់ ឈ្មោះ [redacted] **តារា** ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។ ដោយសារជម្ងឺរបស់ខ្លួនមានភាពប្រសើរឡើង កន្លែងធ្វើការបានផ្តល់ប្រាក់បៀវត្ស ខ្លួនមានលទ្ធភាពចិញ្ចឹមកូនបាន។

**+ចំពោះបណ្តឹងតប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣**

**-ការអះអាងរបស់ចុងចម្លើយ និងជាដើមបណ្តឹងតប ឈ្មោះ [redacted] ទិត តំណាងដោយអាណត្តិដោយមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖**

មូលហេតុនៃការសុំទុកជាមោឃៈនូវពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចាន់លីនណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២៣ ជាអសារបង់ ដោយសារតែកូនក្តីខ្លួន និងចុងបណ្តឹងតបបានចុះកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២២ ដែលមានខ្លឹមសារព្រមព្រៀងគ្នាថាប្រគល់កូនឈ្មោះ [redacted] តារា និងកូនឈ្មោះ [redacted] សំណាង ទៅចុងបណ្តឹងតប ហើយធ្វើឡើងដោយកូនក្តីខ្លួនមានសតិមិនល្អ ទើបតែជាពីជម្ងឺ មានបញ្ហាស្មារតី។ ចំពោះលុយចំនួន ១៣០.០០០ ដុល្លារអាមេរិក កូនក្តីខ្លួនពុំបានដឹងទេ។ មកដល់ពេលនេះកូនក្តីខ្លួនបានឯកភាពលែងលះ និងប្រគល់កូនឲ្យទៅដើមចោទ និងជាចុងបណ្តឹងតប ចំពោះបំណុលកូនក្តីខ្លួនមិនឯកភាពទេ។

ខ្លួននៅតែរក្សាការអះអាងដូចខាងលើដដែល។ ការទាមទារនេះដោយហេតុថាកិច្ចព្រមព្រៀងចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២២ ដែលជាកិច្ចព្រមព្រៀងប្រគល់កូនចំនួន០២នាក់ ឲ្យទៅចុងបណ្តឹងតប និងទី២ ឲ្យទទួលស្គាល់ថាលុយចំនួន ១៣០.០០០ដុល្លារអាមេរិក គឺគាត់បានចូលរួមខ្ចីពីគេ ហើយពេលនោះកូនក្តីខ្លួនទើបតែជាពីជម្ងឺ ប៉ះពាល់សរសៃខួរក្បាល សតិមិនល្អ។

ការទាមទារនេះ ដោយសារតែកូនក្តីខ្លួនមានលទ្ធភាពចិញ្ចឹមកូន និងអាចឲ្យកូនរៀនសូត្របាន និងមានប្រាក់ឧបត្ថម្ភជារៀងរាល់ខែពីកន្លែងធ្វើការងាររបស់កូនក្តីខ្លួន។ កូនប្រុសឈ្មោះ [redacted] តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ជាកូនបង្កើតរបស់ខ្លួន។ តែនៅពេលទាញហេតុផលផ្ទាល់មាត់ ចុងចម្លើយ និងជាដើមបណ្តឹងតបបានបោះបង់ការទាមទារ ដោយប្រគល់កូនទាំង២ឲ្យទៅដើមចោទ និងជាចុងបណ្តឹងតប។



Scanned with CamScanner

ចំពោះលុយចំនួន ៥០.០០០ដុល្លារអាមេរិក នេះ គឺជាលុយដែលរកបាន លុយសល់ពីមុខរបររកស៊ី និង ធ្វើការជាំគ្នារបស់កូនក្តីខ្លួនដែលបានពីការរកស៊ីជុំគ្នា។

ប្រាក់ខែដែលបានមកពីការលក់ដី គឺលក់ដីដែលមានអាសយដ្ឋាននៅភូមិស្មៅខ្ចី ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ ហើយនៅសល់ប្រាក់ខ្លះសល់ពីថ្លៃព្យាបាលជម្ងឺរបស់កូនក្តីខ្លួន។ ចំពោះការបញ្ជាក់នេះ ក៏ខ្លួនពុំច្បាស់ថាសល់ប៉ុន្មានដែរ។

សុំឲ្យតុលាការសម្រេចតាមការទាមទារក្នុងបណ្តឹងតប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ របស់ខ្លួន។

**- ការអះអាងរបស់ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted]ចាន់លីនណា តំណាងដោយអាណត្តិដោយមេធាវី [redacted] និងមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖**

ខ្លួនមិនឯកភាពនិងការអះអាងរបស់ដើមបណ្តឹងតបនោះទេ ព្រោះកិច្ចព្រមព្រៀងនោះមានការវាយត្រា និងបានធ្វើនៅចំពោះមុខចៅសង្កាត់ត្រឹមត្រូវ។

ចំពោះលុយចំនួន១៣០.០០០ដុល្លារអាមេរិក នោះ គឺខ្លួនបានខ្ចីលុយលើកទី១ចំនួន ៣០.០០០ដុល្លារអាមេរិក ពីប្អូនរបស់ខ្លួន ពុំបានធ្វើលិខិតស្នាមអ្វីទេ ដើម្បីមើលជម្ងឺ និងលើកទី២ ខ្ចីប្រាក់ចំនួន ២០០០០ដុល្លារអាមេរិក ដើម្បីយកប្តូរលលាក្បាល មានផ្តិតមេដៃ និងលើកទី៣ បានខ្ចីប្រាក់ចំនួន ៨០.០០០ដុល្លារអាមេរិក ដើម្បីបើកមុខរបររកស៊ីចិញ្ចឹមកូន និងមើលថែរជម្ងឺរបស់គាត់រាល់ថ្ងៃ ដោយមានដើមបណ្តឹងតប ចូលរួមខ្ចីជាមួយខ្លួនដែរ។ ចំពោះភស្តុតាងពីការខ្ចីលុយទាំងអស់នេះ គឺខ្លួនមានឯកសារដាក់ជូនតុលាការពិនិត្យត្រឹមត្រូវ។

លោកមេធាវី [redacted] បានសួរថា ដីស្ថិតនៅភូមិស្មៅខ្ចី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ដែលជាទ្រព្យរួម បានលក់ហើយឬនៅ? និងលក់បានក្នុងតម្លៃប៉ុន្មាន? លក់មុនពេលគ្រោះថ្នាក់ឆក់ខ្សែភ្លើង ឬក្រោយពេលគ្រោះថ្នាក់ឆក់ខ្សែភ្លើង?

ដីដែលស្ថិតនៅភូមិស្មៅខ្ចី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ជាដីទ្រព្យរួមមែន ហើយខ្លួនបានលក់មែន គឺលក់បានលុយចំនួនជាង៦០.០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក មិនចាំថ្ងៃខែឆ្នាំ និងមានឯកសារលក់ដីត្រឹមត្រូវ។ ក្រោយលក់បានខ្លួនដកប្រាក់ចំនួន ៥០០០០ដុល្លារអាមេរិក ទៅសងប្អូន ហើយលក់នៅក្រោយពេលគ្រោះថ្នាក់ចរាចរណ៍។ ចំពោះភស្តុតាងខ្លួននឹងដាក់ជូននៅពេលក្រោយ។

កិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ គឺពិតជាបានធ្វើមែន។ នៅពេលនោះខ្លួនពុំបានបង្ខំឲ្យដើមបណ្តឹងតបធ្វើកិច្ចព្រមព្រៀងនោះទេ ដោយខ្លួនបាននិយាយជាមួយម្តាយគាត់រួចហើយ ទើបគាត់នាំកូនប្រុសគាត់មកធ្វើកិច្ចព្រមព្រៀងនេះ។ នៅពេលនោះដើមបណ្តឹងតបពិតជាឈឺ និងមានសតិមិនគ្រប់គ្រាន់ តែគាត់បានសួរនាំ និងទារប្រាក់ខែរបស់គាត់ពីខ្លួន ហើយខ្លួនក៏បានប្រាប់ទៅម្តាយរបស់គាត់ថា បើយកទាល់តែលែងលះគ្នាសិន។ ពេលនោះមានម្តាយចូលរួមដែរ តែគេមិនឲ្យម្តាយចូលរួមជាមួយទេ គឺឲ្យតែខ្លួន និងដើមបណ្តឹងតបនោះទេ។

កូនឈ្មោះ [redacted]តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ជាកូនបង្កើតរបស់ខ្លួនមែន។ ខ្លួនមិនឯកភាពឲ្យគាត់នោះទេ ព្រោះគាត់កំពុងមានជម្ងឺ គ្មានលទ្ធភាពចិញ្ចឹមកូននោះទេ។ខ្លួនអាចមានលទ្ធភាពចិញ្ចឹមកូនគ្រប់គ្រាន់។

ចំពោះការទាមទារប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ដែលដើមបណ្តឹងតបបានអះអាងនោះ គឺមិនពិតនោះទេ គឺមានតែបំណុល។ ចំពោះលុយសល់ពីការមើលជម្ងឺរបស់គាត់នោះ គឺពុំមានទេ ព្រោះខ្លួននៅដេកមើលគាត់ឈឺរហូតមក។

**៤. ចំណុចគ្មានវិវាទ ៖ គូភាគីឯកភាពគ្នា**

-លែងលះពីគ្នា។

-ឲ្យដើមចោទជាអ្នករ៉ាប់រងបំណុល។



Scanned with CamScanner

-ទទួលស្គាល់ថាពិតជាបានធ្វើកិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន។

**៥. ចំណុចមានវិវាទ៖**

-ដើមចោទទាមទារសិទ្ធិអំណាចមេបាលើកូនទាំង២ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។ ចុងចម្លើយពុំឯកភាពតាមការស្នើសុំរបស់ដើមចោទឡើយ ដោយចុងចម្លើយពុំឯកភាពក្នុងការផ្តល់សិទ្ធិគ្រប់គ្រងកូនទាំង២នាក់ខាងលើឲ្យដើមចោទទេ គឺខ្លួនសុំសិទ្ធិគ្រប់គ្រងកូនម្នាក់ ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។ តើការទាមទាររបស់ដើមចោទ មានហេតុផលត្រឹមត្រូវតាមច្បាប់ដែរឬទេ?

-ដើមចោទ និងជាចុងបណ្តឹងតបអះអាងថាបានខ្ចីប្រាក់ចំនួន ៥០០០០ដុល្លារអាមេរិក ដើម្បីមើលជម្ងឺចុងចម្លើយ និងជាដើមបណ្តឹងតប និងបានខ្ចីប្រាក់ចំនួន ៨០.០០០ដុល្លារអាមេរិក ដើម្បីបើករបររកស៊ី សរុបចំនួន ១៣០០០០ ដុល្លារអាមេរិក រីឯចុងចម្លើយ និងជាដើមបណ្តឹងតប បានបដិសេធដោយសារតែការមើលជម្ងឺអស់តែ ៣០.០០០ដុល្លារអាមេរិកប៉ុណ្ណោះ នៅមន្ទីរពេទ្យចារី ប្រទេសវៀតណាមក្រៅពីនេះពុំមានខ្ចីប្រាក់អ្វីទៀតទេ។ តើការទាមទាររបស់ដើមចោទ មានហេតុផលត្រឹមត្រូវតាមច្បាប់ដែរឬទេ?

-ដើមបណ្តឹងតបបានអះអាងថាមានដីមួយកន្លែងនៅភូមិស្មៅខ្ចី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ជាដីទ្រព្យរួម រីឯចុងបណ្តឹងតបបានអះអាងថាដីបានលក់ហើយ ដើម្បីមើលជម្ងឺរបស់ដើមបណ្តឹងតប។ តើការទាមទាររបស់ដើមបណ្តឹងតប មានហេតុផលត្រឹមត្រូវតាមច្បាប់ដែរឬទេ?

-ដើមបណ្តឹងតបបានអះអាងថាកូនក្តីខ្លួនអំឡុងពេលធ្វើកិច្ចសន្យាកូនក្តីខ្លួនមានសតិមិនគ្រប់គ្រាន់ រីឯចុងបណ្តឹងតបអះអាងថាមានសតិគ្រប់គ្រាន់ និងមានម្តាយចូលរួមផងដែរ។ តើការទាមទាររបស់ដើមបណ្តឹងតប មានហេតុផលត្រឹមត្រូវតាមច្បាប់ដែរឬទេ?

-ដើមបណ្តឹងតបទាមទារប្រាក់ចំនួន ៥០.០០០ដុល្លារអាមេរិក រីឯចុងបណ្តឹងតបបដិសេធថាគ្មានលុយនោះទេ។ តើការទាមទាររបស់ដើមបណ្តឹងតប មានហេតុផលត្រឹមត្រូវតាមច្បាប់ដែរឬទេ?

## II.ការពិនិត្យភស្តុតាង

- **ភស្តុតាងជាឯកសាររបស់គូភាគី៖**

**ភស្តុតាងជាឯកសាររបស់ដើមចោទ និងជាចុងបណ្តឹងតប**

១.សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ០៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយអភិបាលខណ្ឌពោធិ៍សែនជ័យ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨(ថតចម្លង)។

២.សេចក្តីចម្លងសំបុត្រកំណើតលេខ១៧៩ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] តារា ចេញដោយអភិបាលខណ្ឌពោធិ៍សែនជ័យ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨(ថតចម្លង)។

៣.សេចក្តីចម្លងសំបុត្រកំណើតលេខ៩២៤ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] សំណាង ចេញដោយអភិបាលខណ្ឌពោធិ៍សែនជ័យ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨(ថតចម្លង)។

៤.សៀវភៅស្នាក់នៅលេខ២៤៧៧ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤(ថតចម្លង)។

៥.កិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២(ថតចម្លង)។

៦.លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣(ថតចម្លង)។

៧.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០។

៨.កិច្ចសន្យាបង្កើតហ៊ុយប៉ូតែក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១។



Scanned with CamScanner

ភស្តុតាងជាឯកសាររបស់ចុងចម្លើយ និងជាដើមបណ្តឹងតប

១.ពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ចាន់លីនណា។

២.ពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ខាន់។

៣.កិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] ទិត និងឈ្មោះ [redacted] ចាន់លីណា។

៤.ឯកសាររបស់មន្ទីរពេទ្យប្រទេសវៀតណាមឈ្មោះ [redacted] ANH ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ ចំនួន ០៧សន្លឹក(ថតចម្លង)។

៥.ឯកសាររបស់មន្ទីរពេទ្យប្រទេសវៀតណាមឈ្មោះ [redacted] ANH ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ចំនួន ០៦សន្លឹក(ថតចម្លង)។

៦.តារាងសរុបចំណាយដែលត្រូវបើកសាច់ប្រាក់ពីធនាគារសម្រាប់នាយកដ្ឋានទំនាក់ទំនងសាធារណៈ លេខ២៧៨៦ ហិរ.គន ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គិសនី(ថតចម្លង)។

៧.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០០៨៩៩៤០៩ សុពលភាព ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ របស់ឈ្មោះ [redacted] ខាន់(ថតចម្លង)។

៨.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០០៦៨៦១៨០ សុពលភាព ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០៣២ របស់ឈ្មោះ [redacted] ស្រីមុំ(ថតចម្លង)។

## III.សំអាងហេតុ

ផ្អែកតាមលទ្ធផល នៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១.ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីនណា និងចុងចម្លើយឈ្មោះ [redacted] ទិត បានរស់នៅជាមួយគ្នាជាប្តីប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់នៅអំឡុងឆ្នាំ២០១៤ ដូចមានបញ្ជាក់ក្នុងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ០៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយអភិបាលខណ្ឌពោធិ៍សែនជ័យ និងតាមការបញ្ជាក់តាមរយៈការអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ និងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលលើបណ្តឹងតប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ឃើញថាមានភាពត្រឹមត្រូវតាមផ្លូវច្បាប់ ដូច្នេះការសុំលែងលះនេះតុលាការអាចទទួលយកមកពិចារណា និងសម្រេចបាន តាមមាត្រា៩៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

២.ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីនណា បានអះអាងថា សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ទិត ដោយមូលហេតុថា នៅអំឡុងឆ្នាំ២០២០ ចុងចម្លើយបានជួបគ្រោះថ្នាក់ការងារ ឆក់ខ្សែភ្លើងធ្លាក់ពីលើបង្គោលភ្លើង ខ្លួនបានយកចុងចម្លើយទៅព្យាបាលនៅប្រទេសវៀតណាម ជម្ងឺគាត់បានធូរស្រាល តែស្មារតីមិនដូចមុនឡើយ មិនអាចវិលទៅធ្វើការដូចធម្មតាបានដូចមុនទេ។ លុះមកដល់ខ្មែរវិញខ្លួនមើលថែរគាត់បានមួយរយៈដោយខ្លួនរវល់ថែរកូននិងលក់ដូរមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ថែរប្តីបាន មូលហេតុដែលខ្លួនលែងលះព្រោះខ្លួនមិនមានលទ្ធភាពមើលថែគាត់បាន ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត សព្វថ្ងៃខ្លួននិងចុងចម្លើយបានរស់នៅបែកសង្វាសគ្នា០៣ឆ្នាំមកហើយ។

ចុងចម្លើយ និងជាដើមបណ្តឹងតបឯកភាពលែងលះពីដើមចោទ ដោយសារការរួមរស់ជាមួយគ្នា មិនអាចរួមភេទជាមួយគ្នាបានធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ហើយសព្វថ្ងៃខ្លួនរស់នៅបែកសង្វាសគ្នាចំនួន០៣ឆ្នាំដូចការលើកឡើងរបស់ដើមចោទ។

តុលាការយល់ឃើញថា ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីនណា និងចុងចម្លើយឈ្មោះ [redacted] ទិត ពិតជាមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍តាមការព្រមព្រៀង។



Scanned with CamScanner

ដូច្នេះ តុលាការគប្បីសម្រេចឲ្យគូភាគីលែងលះគ្នាតាមការព្រមព្រៀង ស្របតាមមាត្រា ៩៧៩[1] វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី។

គូភាគីអះអាងថាបានរស់នៅបែកសង្វាសគ្នារយៈពេល០៣ឆ្នាំមកហើយ ដូចនេះតុលាការមិនគប្បីលើកយកមាត្រា៩៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ដើម្បីសម្រេចឲ្យដើមចោទស្ថិតនៅក្នុងភាពមេម៉ាយក្នុងរយៈពេល ១២០(មួយរយម្ភៃ)ថ្ងៃ ឡើយ។

**៣. អំណាចមេបាលើកូន៖** អំឡុងពេលនៃការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធគូភាគីមានកូនចំនួន ០២នាក់ ឈ្មោះ [redacted]តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted]សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ដើមចោទ និងជាចុងបណ្ដឹងតបបានអះអាងថា មូលហេតុដែលខ្លួនសុំសិទ្ធិគ្រប់គ្រងកូនទាំង០២នាក់ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ដោយសារកូនទាំងពីរជាកូនបង្កើតរបស់ខ្លួន ចុងចម្លើយនិងជាដើមបណ្ដឹងតបមានជម្ងឺមិនអាចគ្រប់គ្រងរក្សាកូនបាន និងពុំមានលទ្ធភាពគ្រប់គ្រាន់សម្រាប់មើលថែរកូនឡើយ ចុងចម្លើយ និងជាដើមបណ្ដឹងតបអាចមកលេងសួរសុខទុក្ខកូន ឬយកកូនទៅលេងបាននៅពេលដែលកូនសម្រាកពីការរៀនសូត្រ ខ្លួនមិនទាមទារអាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនឡើយ ខ្លួនមានលទ្ធភាពក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនរហូតដល់កូនមានការងារធ្វើ។ ចំណែកនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើបណ្ដឹងតប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ដើមចោទ និងជាចុងបណ្ដឹងតប បានធ្វើការអះអាងថា កូនឈ្មោះ [redacted]តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ជាកូនបង្កើតរបស់ខ្លួន។ ខ្លួនមិនឯកភាពឲ្យទៅចុងចម្លើយ និងជាដើមបណ្ដឹងតបទេ ព្រោះគាត់កំពុងតែមានជម្ងឺ គ្មានលទ្ធភាពចិញ្ចឹមកូននោះទេ។ ខ្លួនមានលទ្ធភាពចិញ្ចឹមកូនបានគ្រប់គ្រាន់។

ចុងចម្លើយ និងជាដើមបណ្ដឹងតបបានធ្វើការអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ថា ខ្លួនពុំឯកភាពក្នុងការផ្ដល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ខាងលើឲ្យដើមចោទទេ គឺខ្លួនសុំសិទ្ធិគ្រប់គ្រងកូនម្នាក់ឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣។ ដោយសារជម្ងឺរបស់ខ្លួនមានភាពប្រសើរឡើង កន្លែងធ្វើការបានផ្ដល់ប្រាក់បៀវត្ស ខ្លួនមានលទ្ធភាពចិញ្ចឹមកូនបាន។ រីឯនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើបណ្ដឹងតប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ចុងចម្លើយនិងជាដើមបណ្ដឹងតបបានអះអាងថា កូនក្ដីខ្លួនមានលទ្ធភាពចិញ្ចឹមកូន និងអាចឲ្យកូនទៅរៀនសូត្របាន មានប្រាក់ឧបត្ថម្ភជារៀងរាល់ខែពីកន្លែងធ្វើការងាររបស់កូនក្ដីខ្លួន។ ម្យ៉ាងកូនឈ្មោះ [redacted]តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ជាកូនបង្កើតរបស់ខ្លួន។

បើតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ដើមចោទ និងជាចុងបណ្ដឹងតប បានធ្វើការអះអាងថា មូលហេតុដែលខ្លួនសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ ឈ្មោះ [redacted]តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ កូនទាំងពីរនាក់ ជាកូនរបស់ខ្លួន ជាមួយចុងចម្លើយ និងជាដើមបណ្ដឹងតបប្រាកដមែន។ ដោយសារប្ដីខ្លួនមានជម្ងឺមិនអាចគ្រប់គ្រងថែរក្សាកូនបាន ខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនរហូតដល់កូនមានការងារធ្វើ។ ខ្លួនមានមុខរបរលក់ដូរនៅផ្សារ អាចមានពេលវេលាគ្រប់គ្រាន់សម្រាប់មើលថែរកូន។ ចំណែកចុងចម្លើយ និងជាដើមបណ្ដឹងតបបានធ្វើការអះអាងថា ឯកភាពប្រគល់កូនទាំងពីរនាក់ទៅឲ្យដើមចោទ និងជាចុងបណ្ដឹង តែសុំពេលទៅសួរសុខទុក្ខកូន។

[1] មាត្រា៩៧៩ វាក្យខណ្ឌ២ (ការលែងលះតាមការព្រមព្រៀង) នៃក្រមរដ្ឋប្បវេណីចែងថា៖ តុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ។



Scanned with CamScanner

តុលាការយល់ឃើញថា នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទនិងជាចុងបណ្តឹងតប និងចុងចម្លើយនិងជាដើមបណ្តឹងតប បានព្រមព្រៀងកំណត់អំពីអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងកូនឈ្មោះ ទិត សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ រួចរាល់ហើយ ដូច្នេះស្របតាមបញ្ញត្តិមាត្រា **១០៣៧[2]កថាខណ្ឌទី១**នៃក្រមរដ្ឋប្បវេណី តុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី។ ចំណុចនេះតុលាការក៏បានពិនិត្យឃើញផងដែរថា ភាគីខាងឪពុក ពុំមានលទ្ធភាពក្នុងការចិញ្ចឹមកូនបានល្អឡើយក្នុងការមើលថែរទាំកូនឲ្យបានល្អ ក្នុងការចិញ្ចឹមកូន ម្យ៉ាងទៀតកូននៅជាអនីតិជនដែលពុំចាំបាច់ត្រូវការមើលថែរទាំដោយយកចិត្តទុកដាក់ និងតម្រូវការក្នុងការសិក្សា ចំណុចនេះតុលាការពិនិត្យឃើញថាម្តាយរបស់កូនទាំង២មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមកូនដូចការលើកឡើងប្រាកដមែន។

**៤. សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន**

**-អំពីការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន៖** ចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ [redacted] ទិត ដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនទាំងពីរបានតាមវេលាសមរម្យ ឬសម្រាកពីការរៀនសូត្រ និងជូនដំណឹងជាមុនដល់ដើមចោទ ហើយដើមចោទឈ្មោះ [redacted] ចាន់លីនណា បានអនុញ្ញាត និងឯកភាពតាមការព្រមព្រៀង ដូចមាននៅក្នុងការអះអាងរបស់គូភាគីនៅកាលបរិច្ឆេទ នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣។

ដូច្នេះតុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមបញ្ញត្តិមាត្រា**១០៤០** នៃក្រមរដ្ឋប្បវេណី។

**៥.**តាមការអះអាងរបស់គូភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីណា បានយល់ព្រមរ៉ាប់រងទទួលខុសត្រូវសងបំណុលរួមដែលនៅសល់ពីការខ្ចីបង្កើតមុខរបររកស៊ីនិងមើលជម្ងឺចំនួន ១៣០.០០០(ដប់បីម៉ឺន)ដុល្លារអាមេរិក។ ចំណែកចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ [redacted] ទិត បានឯកភាពតាមការលើកឡើងរបស់ដើមចោទ។

តុលាការពិនិត្យឃើញថាមានការពាក់ព័ន្ធនឹងតតិយជនលើការខ្ចីប្រាក់ ដូច្នេះតុលាការពុំគប្បីលើកមកពិនិត្យពិចារណាឡើយ។

**៦.**ចុងចម្លើយនិងជាដើមបណ្តឹងតប សុំទុកជាមោឃៈនូវពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចាន់លីនណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ជាអសារបង់ ដោយអះអាងថា មូលហេតុនៃការសុំទុកជាមោឃៈនូវពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចាន់លីនណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ជាអសារបង់ ដោយសារតែកូនក្តីខ្លួន និងចុងបណ្តឹងតបបានចុះកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដែលមានខ្លឹមសារព្រមព្រៀងគ្នាថាប្រគល់កូនឈ្មោះ [redacted] តារា និងកូនឈ្មោះ [redacted] សំណាង ទៅចុងបណ្តឹងតប ហើយធ្វើឡើងដោយកូនក្តីខ្លួនមានសតិមិនល្អ ទើបតែជាពីជម្ងឺមានបញ្ហាស្មារតី។ ចំពោះលុយចំនួន១៣០០០០ដុល្លារអាមេរិក កូនក្តីខ្លួនពុំបានដឹងទេ។ មកដល់ពេលនេះ កូនក្តីខ្លួន បានឯកភាពលែងលះ និងប្រគល់កូនឱ្យទៅ ដើមចោទ និងជាចុងបណ្តឹងតប ចំពោះបំណុលកូនក្តីខ្លួនមិនឯកភាពទេ។

ដើមចោទ និងជាចុងបណ្តឹងតប បដិសេធថាខ្លួនមិនឯកភាពនឹងការអះអាងរបស់ដើមបណ្តឹងតបនោះទេ ព្រោះកិច្ចព្រមព្រៀងនោះមានការវាយត្រា និងបានធ្វើនៅចៅសង្កាត់ត្រឹមត្រូវ។

---

[2] មាត្រា១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ចែងថា៖ "(១) បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្នាក់ ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ, (២) ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន, (៣) បើការពិភាក្សានៃកថាខណ្ឌទី១ ឬ កថាខណ្ឌទី២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ"។

[3] មាត្រា ១០៤០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមរដ្ឋប្បវេណី ចែងថា៖ (១) ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។[....]



Scanned with
CamScanner

ចំពោះលុយចំនួន១៣០.០០០ ដុល្លារអាមេរិកនោះ គឺខ្លួនបានខ្ចីលុយលើកទី១ ចំនួន៣០.០០០ ដុល្លារអាមេរិក ពីប្អូនរបស់ខ្លួន ពុំបានធ្វើលិខិតស្នាមអ្វីទេ ដើម្បីមើលជម្ងឺ និងលើកទី២ ខ្ចីប្រាក់ចំនួន ២០០០០ ដុល្លារអាមេរិក ដើម្បីយកប្តូរលលាក្បាល មានផ្តិតមេដៃ និងលើកទី៣ បានខ្ចីប្រាក់ចំនួន ៨០០០០ ដុល្លារអាមេរិក ដើម្បីបើកមុខរបររកស៊ីចិញ្ចឹមកូន និងមើលថែជម្ងឺរបស់គាត់រាល់ថ្ងៃ ដោយមានដើមបណ្តឹងតប ចូលរួមខ្ចីជាមួយខ្លួនដែរ។ ចំពោះភស្តុតាងពីការខ្ចីលុយទាំងអស់នេះ គឺខ្លួនមានឯកសារដាក់ជូនតុលាការពិនិត្យត្រឹមត្រូវ។

ដីដែលបានស្ថិតនៅភូមិស្មៅខ្ចី ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ជាដីទ្រព្យរួមមែន ហើយខ្លួនបានលក់មែន គឺលក់បានលុយចំនួនជាង៦០០០០ ដុល្លារអាមេរិក មិនចាំថ្ងៃខែឆ្នាំ និងមានឯកសារលក់ដីត្រឹមត្រូវ។ ក្រោយលក់បានខ្លួនដកប្រាក់ចំនួន៥០០០០ដុល្លារអាមេរិក ទៅសងប្អូន ហើយលក់នៅក្រោយពេលគ្រោះថ្នាក់។ ចំពោះភស្តុតាងខ្លួននឹងដាក់ ជូនតុលាការនៅពេលក្រោយ។

យល់ឃើញថាពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ដែលដើមចោទបានប្តឹងលែងលះពីចុងចម្លើយស្របតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប មានខ្លឹមសារព្រមព្រៀងគ្នាថាប្រគល់កូនឈ្មោះ ទិត តារា និងកូនឈ្មោះ [redacted] សំណាង ទៅចុងបណ្តឹងតប និងភាគីប្រពន្ធជាអ្នករ៉ាប់រងចំពោះបំណុលចំនួន១៣០.០០០ដុល្លារអាមេរិក។ ថ្វីត្បិតតែធ្វើឡើងដោយដើមបណ្តឹងតបមានសតិមិនល្អ ទើបតែជាពីជម្ងឺមានបញ្ហាស្មារតី តែការចុះកិច្ចសន្យាព្រមព្រៀងនោះក៏មានការចូលរួមពីម្តាយដែលជាអាណាព្យាបាលរបស់ដើមបណ្តឹងតប ព្រមទាំងមានការវាយត្រា និងបានធ្វើនៅចៅសង្កាត់ត្រឹមត្រូវផងដែរ។

ការទាមទាររបស់ចុងចម្លើយ និងជាដើមបណ្តឹងតបមិនមានភាពចាំបាច់ឲ្យតុលាការលើកមកពិចារណាទេ ដោយហេតុថាចុងចម្លើយ និងជាដើមបណ្តឹងតបមិនបានដាក់ភស្តុតាងច្បាស់លាស់មកតុលាការឡើយ ម្យ៉ាងនៅក្នុងកិច្ចព្រមព្រៀងនោះមានពាក់ព័ន្ធនឹងភាគីតតិយជន និងមិនមានការសម្រេចសេចក្តីណាមួយលើការលុបចោលកិច្ចព្រមព្រៀងនោះឡើយ ចំណុចនេះតុលាការមិនលើកយកមកពិនិត្យពិចារណា និងសម្រេចឡើយ។

**៧**.ចុងចម្លើយ និងជាដើមបណ្តឹងតបសុំឱ្យតុលាការចេញសេចក្តីសម្រេចលុបចោលកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រវាងខ្លួន និងឈ្មោះ [redacted] ចាន់លីនណា ដោយអះអាងថាកិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដែលជាកិច្ចព្រមព្រៀងប្រគល់កូនចំនួនពីរនាក់ទៅឱ្យចុងបណ្តឹងតប និងទី២ ទទួលស្គាល់ថាគាត់ ជំពាក់ ១៣០.០០០ដុល្លារអាមេរិក គឺគាត់បានចូលរួមខ្ចីពីគេ ហើយពេលនោះកូនក្តីខ្លួន ទើបតែបានជាសះស្បើយពីជំងឺ ប៉ះពាល់សរសៃខួរក្បាល សតិមិនល្អ។ ចំណែកដើមចោទ និងជាចុងបណ្តឹងតបបានបដិសេធថាកិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ពិតជាបានធ្វើមែន។ នៅពេលនោះ ខ្លួនពុំបានបង្ខំដើមបណ្តឹងតបធ្វើកិច្ចព្រមព្រៀងនេះទេ ដោយខ្លួនបាននិយាយជាមួយម្តាយគាត់រួចហើយ ទើបគាត់បាននាំកូនប្រុសរបស់គាត់មកធ្វើកិច្ចព្រមព្រៀងនេះ។ នៅពេលនោះដើមបណ្តឹងតបពិតជាឈឺមែន និងមានសតិមិនគ្រប់គ្រាន់ តែគាត់បានសួរនាំ និងទារប្រាក់ខែរបស់គាត់ពីខ្លួន ហើយខ្លួនក៏បានប្រាប់ទៅម្តាយរបស់គាត់ថា បើយកទាល់តែលែងលះគ្នាសិន។ ពេលនោះមានម្តាយចូលរួមដែរ តែមិនបានផ្តិតមេដៃចូលរួមជាមួយទេ គឺឱ្យតែខ្លួន និងដើមបណ្តឹងតបចូលរួម។

តុលាការយល់ឃើញថាកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រវាងដើមបណ្តឹងតប និងចុងបណ្តឹងតប មានខ្លឹមសារព្រមព្រៀងគ្នាថាប្រគល់កូនឈ្មោះ [redacted] តារា និងកូនឈ្មោះ [redacted] សំណាង ទៅចុងបណ្តឹងតប និងចំពោះបំណុលចំនួន ១៣០.០០០ ដុល្លារអាមេរិក នោះ ថ្វីត្បិតតែធ្វើឡើងដោយដើមបណ្តឹងតបមានសតិមិនល្អ ទើបតែជាពីជម្ងឺមានបញ្ហាស្មារតី តែការចុះកិច្ចព្រមព្រៀងនោះក៏មានការចូលរួមពីម្តាយដែលជាអាណាព្យាបាលរបស់ដើមបណ្តឹងតប ព្រមទាំងមានការវាយត្រា និងបានធ្វើនៅចៅសង្កាត់ត្រឹមត្រូវ។



Scanned with CamScanner

នៅក្នុងកិច្ចព្រមព្រៀងរវាងដើមចោទ និងជាចុងបណ្តឹងតប និងចុងចម្លើយ និងជាដើមបណ្តឹងតប មានការចូលរួមពីម្តាយដែលជាតតិយជន និងមិនមានភស្តុតាងច្បាស់លាស់ដាក់មកតុលាការពិនិត្យពិចារណាឡើយ។

ចំណុចនេះតុលាការយល់ឃើញថាការទាមទាររបស់ចុងបណ្តឹងតប មានភាពស្មុគស្មាញលើការទាមទារបែងចែកទ្រព្យរួម ព្រមទាំងបដិសេធនូវកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ផងដែរ ដែលតម្រូវឲ្យគូភាគីអះអាងក្នុងការទាមទារ ឬផ្តល់ភស្តុតាងផ្សេងផងដែរក្នុងការទាមទារនេះ ដោយឡែកទ្រព្យសម្បត្តិរួមទាំងនេះ មានពាក់ព័ន្ធនឹងតតិយជនទី៣ផងដែរ ដែលតម្រូវឲ្យភាគីប្តឹងទាមទារក្នុងការបែងចែកទ្រព្យសម្បត្តិរួមនេះ។

៨.ចុងចម្លើយ និងជាដើមបណ្តឹងតបទាមទារកូនប្រុសច្បង ឈ្មោះ [redacted] តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដោយអះអាងពីមូលហេតុនៃការទាមទារថា ដោយសារតែកូនក្តីខ្លួន មានលទ្ធភាពចិញ្ចឹមកូន និងអាចឱ្យកូនរៀនសូត្របាន និងមានប្រាក់ឧបត្ថម្ភ ជារៀងរាល់ខែពីកន្លែងធ្វើការរបស់កូនក្តីខ្លួន។ កូនប្រុសឈ្មោះ[redacted]តារា កើតនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១៣ ជាកូនបង្កើតរបស់ខ្លួន។ តែនៅពេលទាញហេតុផលផ្ទាល់មាត់ ចុងចម្លើយនិងជាដើមបណ្តឹងតប បានបោះបង់ការទាមទារ ដោយប្រគល់កូនទាំងពីរឈ្មោះ [redacted]តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ[redacted]សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ទៅឱ្យ ដើមចោទ និងជាចុងបណ្តឹងតប គប្បីតុលាការពិចារណាតាមការអះអាងនេះ។

ដើមចោទ និងជាចុងបណ្តឹងតបបានអះអាងសុំសិទ្ធិគ្រប់គ្រងលើកូនទាំង០២នាក់ និងអនុញ្ញាតឲ្យចុងចម្លើយនិងជាដើមបណ្តឹតប មកសួរសុខទុក្ខកូន ឬយកកូនទៅលេងបាននៅពេលដែលកូនសម្រាកពីការរៀនសូត្រ និងមិនទាមទារអាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនឡើយ។

តុលាការយល់ឃើញថាចុងចម្លើយ និងជាដើមបណ្តឹងតបទាមទារកូនប្រុសច្បង ឈ្មោះ [redacted] តារា កើតថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៣ ដោយអះអាងពីមូលហេតុនៃការទាមទារថា ដោយសារតែកូនក្តីខ្លួន មានលទ្ធភាពចិញ្ចឹមកូន និងអាចឱ្យកូនរៀនសូត្របាន និងមានប្រាក់ឧបត្ថម្ភ ជារៀងរាល់ខែពីកន្លែងធ្វើការរបស់កូនក្តីខ្លួន។ តែនៅពេលទាញហេតុផលផ្ទាល់មាត់ ចុងចម្លើយនិងជាដើមបណ្តឹងតប បានបោះបង់ការទាមទារ ដោយប្រគល់កូនទាំងពីរទៅឱ្យ ដើមចោទនិងជាចុងបណ្តឹងតប។ ដើមចោទនិងជាចុងបណ្តឹងតប និងចុងចម្លើយនិងជាដើមបណ្តឹងតប បានព្រមព្រៀងកំណត់អំពីអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] តារា ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងកូនឈ្មោះ [redacted] សំណាង ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ រួចរាល់ហើយ ដូច្នេះស្របតាមបញ្ញត្តិមាត្រា**១០៣៧**[3] **កថាខណ្ឌទី១**នៃក្រមរដ្ឋប្បវេណី តុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៩.**ចុងចម្លើយនិងជាដើមបណ្តឹងតបទាមទារសុំឱ្យឈ្មោះ [redacted] ចាន់លីនណា ប្រគល់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក មកឱ្យខ្លួន ដែលជាប្រាក់បានមកពីការរកស៊ីរួមគ្នា និងប្រាក់ដែលបានមកពីការលក់ដី និងសល់ពីថ្លៃព្យាបាលជម្ងឺ ដោយអះអាងថាចំពោះលុយចំនួន៥០.០០០ដុល្លារអាមេរិកនេះ គឺជាលុយដែលរកបានលុយសល់ពីមុខរបររកស៊ី និងធ្វើការ ផ្សំគ្នារបស់កូនក្តីខ្លួន និងដើមចោទ និងចុងបណ្តឹងតប ឈ្មោះ [redacted] ចាន់លីនណា។

---

[3] មាត្រា១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ចែងថា៖ "(១) បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ, (២) ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន, (៣) បើការពិភាក្សានៃកថាខណ្ឌទី១ ឬ កថាខណ្ឌទី២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ"។

មាត្រា ៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមរដ្ឋប្បវេណី ចែងថា៖ (១) ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។[....]



Scanned with
CamScanner

ប្រាក់ដែលបានមកពីការលក់ដី គឺលក់ដីដែលមានអាសយដ្ឋានស្ថិតនៅភូមិស្មៅខ្ញី ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ ហើយនៅសល់ប្រាក់ខ្លះនៅសល់ពីការថ្លៃព្យាបាលជម្ងឺរបស់កូនក្តីខ្លួន។ ចំពោះការបញ្ជាក់នេះ ក៏ខ្លួនពុំច្បាស់ថានៅសល់ប៉ុន្មានដែរ។

ចំណែកដើមចោទ និងជាចុងបណ្តឹងតបបានបដិសេធថាចំពោះការទាមទារប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ដែលដើមបណ្តឹងតបបានអះអាងនោះ គឺមិនពិតនោះទេ គឺមានតែបំណុល។ ចំពោះលុយនៅសល់ពីការមើលជម្ងឺរបស់គាត់នោះ គឺពុំមានទេ ព្រោះខ្លួនបានចំណាយមើលគាត់ឈឺរហូតមក។

តុលាការយល់ឃើញថា ការទាមទាររបស់ដើមបណ្តឹងតបមិនមានភស្តុតាងណាច្បាស់លាស់បញ្ជាក់ដើម្បីឲ្យតុលាការដើម្បីពិនិត្យពិចារណាទេ ដោយហេតុថាដើមចោទ និងជាចុងបណ្តឹងតបបានអះអាងថាលុយនៅសល់ពីការមើលជម្ងឺរបស់គាត់នោះ គឺពុំមានទេ ព្រោះខ្លួនបានចំណាយមើលដើមបណ្តឹងតបឈឺរហូតមក។

តាមរយៈការនេះអះអាងខាងលើ តុលាការពិនិត្យឃើញថាការទាមទាររបស់ចុងចម្លើយ និងជាដើមបណ្តឹងតបទាក់ទងនឹងទ្រព្យសម្បត្តិរបស់ភាគី ឃើញថាមានភាពស្មុគស្មាញដែលតម្រូវឲ្យភាគីផ្តល់ភស្តុតាងមកតុលាការរួមទាំងបំណុលផ្សេងៗ ក្នុងនោះមានទាំងបំណុល ភាគីម្ចាស់បំណុលដែលជាតតិយជនផងដែរ ពុំគប្បីឲ្យតុលាការលើកមកពិនិត្យពិចារណាឡើយ ទុកលទ្ធភាពឲ្យភាគីប្តឹងទាមទារបែងចែកទ្រព្យនេះ។

១០.បណ្តឹងរបស់ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីណា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តែផ្ទុយនឹងគតិច្បាប់ខ្លះ ដូច្នេះគប្បីតុលាការពិចារណាសម្រេចតាមការទាមទារខ្លះរបស់ដើមចោទ និងជាចុងបណ្តឹងតប។

១១.ចំពោះពាក្យបណ្តឹងតបរបស់ចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ [redacted] ទិត ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ពុំគប្បីឲ្យតុលាការលើកយកមកសម្រេចនៅក្នុងសេចក្តីសម្រេចនេះទេលើការបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាលើការលែងលះ និងការបែងចែកកូនដែលភាគីបានព្រមព្រៀងគ្នាតែប៉ុណ្ណោះ។

**១២.ចំពោះប្រាក់ប្រដាប់ក្តី៖** តាមការអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ និងពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ [redacted] ចាន់លីណា បានយល់ព្រមទទួលបន្ទុកប្រាក់ប្រដាប់ក្តី។ដូចនេះ គប្បីតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១៣.យើងបានព្យាយាមផ្សះផ្សារគូភាគីរួចហើយ ប៉ុន្តែគូភាគីពុំព្រមសះជានឹងគ្នាទេ។

**IV.សេចក្តីសម្រេចបញ្ចប់**

១. ឲ្យដើមចោទ និងជាចុងបណ្តឹងតបនាងឈ្មោះ [redacted] **ចាន់លីនណា** និងចុងចម្លើយឈ្មោះ [redacted] ទិត លែងលះពីគ្នា(តាមការព្រមព្រៀងរបស់គូភាគី)។

២. ប្រគល់សិទ្ធិអំណាចមេបាលើទាំង២នាក់ មានឈ្មោះ [redacted] **តារា** ភេទប្រុស កើតថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យទៅដើមចោទ និងជាចុងបណ្តឹងតបនាងឈ្មោះ [redacted] **ចាន់លីនណា** ជាម្តាយ ជាអ្នកចិញ្ចឹមបីបាច់ គ្រប់គ្រងថែរក្សាកូនៗ។

-ចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ [redacted] **ទិត** ដែលពុំមានអំណាចមេបាលើកូនមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនទាំងពីរបានតាមពេលវេលាសមរម្យ។ ដើមចោទ និងជាចុងបណ្តឹងតប ឈ្មោះ [redacted] **ចាន់លីនណា** ជាអ្នកមានអំណាចមេបាលើកូនទាំងពីរ ត្រូវសម្រប សម្រួល និងបង្កលក្ខណៈងាយស្រួល



Scanned with CamScanner

ដល់ចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ [redacted] **ទិត** ក្នុងការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនតាមពេលវេលាសមរម្យ (តាមការព្រមព្រៀងរបស់គូភាគី)។

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និងជាចុងបណ្ដឹងតប។

សាលក្រមនេះប្រកាស ជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងជាចុងបណ្ដឹងតបឈ្មោះ [redacted] **ចាន់លីនណា** និងចុងចម្លើយឈ្មោះ [redacted] **ទិត**។

ក្នុងករណីដែលត្រូវប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧

បានឃើញ

**ចៅក្រម**

[redacted]

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner